ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០១២៩ រថ.បគអថ.ប្រក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

# ប្រកាស
# ស្តីពី
# ការអនុញ្ញាតឱ្យវិនិយោគអភិវឌ្ឍនិងបង្កើតប្រព័ន្ធទំនាក់ទំនង និងកម្មវិធីទូរសព្ទ សម្រាប់ការបញ្ចូលថាមពល និងការផ្លាស់ប្តូរអាគុយសម្រាប់យានយន្តអគ្គិសនី

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៥/០០៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០៣២១ រថ.អថ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននានា នៃអគ្គនាយកដ្ឋានថាមពល
- បានឃើញប្រកាសលេខ០៣៨៩ រថ.បគអថ.ប្រក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥ ស្តីពីគោលការណ៍ និងនីតិវិធី សម្រាប់គ្រប់គ្រងនិងបញ្ញត្តិលើការអភិវឌ្ឍ និងការធ្វើសេវាកម្មបញ្ចូលថាមពលឱ្យយានយន្តអគ្គិសនី
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

# សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យក្រុមហ៊ុន វ័ន្ត ផៅវ័រ ថេកណឡជី ឯ.ក (OONE POWER TECHNOLOGY CO., LTD.) ចុះបញ្ជីពាណិជ្ជកម្មលេខ ០០០៤០៣០៥ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៩ មានអាសយដ្ឋាន #៩៩៧ ជាន់ទី៤ ផ្លូវបេតុង ក្រុមទី៤ ភូមិប្រេស សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ វិនិយោគអភិវឌ្ឍនិងបង្កើតប្រព័ន្ធទំនាក់ទំនង និងកម្មវិធីទូរសព្ទសម្រាប់ការបញ្ចូលថាមពល និងការផ្លាស់ប្តូរអាគុយសម្រាប់យានយន្តអគ្គិសនី ដែលតទៅនេះហៅថា "**វិនិយោគិន**"។

**ប្រការ២ .-**

វិនិយោគិន ត្រូវមានកិច្ចសន្យាសេវាកម្មបន្តជាមួយអគ្គិសនីកម្ពុជា ដើម្បីទទួលសិទ្ធិវិនិយោគអភិវឌ្ឍ បង្កើត និងគ្រប់គ្រងដំណើរការប្រព័ន្ធទំនាក់ទំនង និងកម្មវិធីទូរសព្ទសម្រាប់ការបញ្ចូលថាមពល និងការផ្លាស់ប្តូរអាគុយយានយន្តអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ .-**

វិនិយោគិន ត្រូវមានអាជ្ញាបណ្ណផ្តល់សេវាកម្មប្រព័ន្ធទំនាក់ទំនង និងកម្មវិធីទូរសព្ទសម្រាប់បម្រើដល់ការបញ្ចូលថាមពល និងការផ្លាស់ប្តូរអាគុយសម្រាប់យានយន្តអគ្គិសនីពី អាជ្ញាធរអគ្គិសនីកម្ពុជា។

**ប្រការ៤ .-**

វិនិយោគិន ត្រូវអនុវត្តតាមប្រកាសលេខ០៣៨៩ រថ.បគអថ.ប្រក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥ របស់ក្រសួងរ៉ែនិងថាមពល ស្តីពីគោលការណ៍ និងនីតិវិធី សម្រាប់គ្រប់គ្រងនិងបញ្ញត្តិលើការអភិវឌ្ឍ និងការធ្វើសេវាកម្មបញ្ចូលថាមពលឱ្យយានយន្តអគ្គិសនី។

**ប្រការ៥ .-**

វិនិយោគិន ដែលស្នើសុំវិនិយោគអភិវឌ្ឍនិងបង្កើតប្រព័ន្ធទំនាក់ទំនង និងកម្មវិធីទូរសព្ទសម្រាប់ការបញ្ចូលថាមពល និងការផ្លាស់ប្តូរអាគុយសម្រាប់យានយន្តអគ្គិសនី ត្រូវបង់កម្រៃសេវាសាធារណៈស្របតាមប្រកាសអន្តរក្រសួងរវាងក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៦ .-**

វិនិយោគិន មិនត្រូវបោះបង់ ប្រគល់ ឬផ្ទេរសិទ្ធិ ក្នុងប្រកាសនេះតទៅភាគីទី៣ ដោយគ្មានការអនុញ្ញាតពីក្រសួងឡើយ។

**ប្រការ៧ .-**

វិនិយោគិន ត្រូវគោរពច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា និងវិធានការនានារបស់ក្រសួងរ៉ែនិងថាមពល។

**ប្រការ៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩ .-**

អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយក នៃអគ្គនាយកដ្ឋានថាមពល អគ្គាធិការ ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា អគ្គនាយកអគ្គិសនីកម្ពុជា នាយកដ្ឋានបច្ចេកទេស និងគោលនយោបាយអាជីវកម្មថាមពល និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែ ពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ហេង-សួរ**

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គិសនីកម្ពុជា
- ដូចប្រការ៩ ដើម្បីអនុវត្ត
- ឯកសារ កាលប្បវត្តិ